CDRI
Cambodia Development Resource Institute

G GEAR
GROWING TOGETHER

# សង្ខេបចក្ខុវិស័យប្រទេសកម្ពុជា

## ការប្រែក្លាយផ្នែកឌីជីថលឆ្ពោះទៅកាន់ឧស្សាហកម្ម ៤.0

“បច្ចេកវិទ្យាឌីជីថល ជួយសម្រួលសកម្មភាពគ្រប់បែបយ៉ាងក្នុងទូទាំងប្រទេស មានតាំងពីទំនាក់ទំនងរវាងប្រជាជន រហូតដល់ ពាណិជ្ជកម្ម សហគ្រាសទើបចាប់ដំណើរការ រហូតដល់គណនេយ្យភាព និងតម្លាភាពរបស់អ្នកផ្តល់សេវាក្នុងស្រុក ក៏ដូចជា សហប្រតិបត្តិការ និងសុខដុមនីយកម្មនៅក្នុង និងរវាងក្រសួង មន្ទីរ ស្ថាប័ន នានា”។

*សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន*
*នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា*

ប្រទេសកម្ពុជា ចាប់ផ្ដើមដំណើរលើមាគ៌ានៃការប្រែក្លាយផ្នែកឌីជីថល ដើម្បីត្រៀមខ្លួនឲ្យបានស្រេចបាច់ សម្រាប់ការធ្វើអន្តរកាលទៅអនុវត្តរបៀបរបបសេដ្ឋកិច្ចឌីជីថលជាចម្បង នៅឆ្នាំ២០២៣។ ក្នុងរបៀបវារៈអភិវឌ្ឍន៍ជាតិ រដ្ឋាភិបាលកម្ពុជាបានផ្តល់អាទិភាពខ្ពស់ដល់ភាពត្រៀមស្រេចបាច់សម្រាប់សេដ្ឋកិច្ចឌីជីថល និងឧស្សាហកម្ម ៤.0 ដូចមានបញ្ជាក់ក្នុង យុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៤ ឆ្នាំ២០១៨-២៣។ ការឈរជើងបាននៅក្នុងពិភពឌីជីថល មិនមែនគ្រាន់តែជាមហិច្ឆតាផ្នែកសេដ្ឋកិច្ចប៉ុណ្ណោះទេ ប៉ុន្តែក៏ចាំបាច់ដែរដើម្បីឲ្យសេដ្ឋកិច្ចជាតិអាចរីកចម្រើនរុងរឿងទៅអនាគត ដោយសារមូលហេតុជាច្រើន៖

១. ដោយមានយុទ្ធសាស្ត្រត្រឹមត្រូវ សេដ្ឋកិច្ចកម្ពុជាដែលប្រែក្លាយជាឌីជីថល អាចជួយជំរុញការផ្លាស់ប្តូរក្នុងរចនាសម្ព័ន្ធ សំដៅឈានទៅអនុវត្តសកម្មភាពកាន់តែចម្រុះបែប មានតម្លៃបន្ថែមច្រើន និងមានផលិតភាពខ្ពស់ ហើយលក្ខណៈទាំងអស់នេះចាំបាច់ណាស់ដើម្បីរក្សាឲ្យមានកំណើនយូរអង្វែង បង្កើតការងារបានច្រើននិងសមរម្យ និងពង្រឹងសមត្ថភាពប្រកួតប្រជែង។ ដំណើរបែបនេះអាចមើលឃើញច្បាស់តាមរយៈលទ្ធផលសេដ្ឋកិច្ចដ៏ល្អត្រចះរបស់ សិង្ហបុរី ចិន ហុងកុង និង កូរ៉េខាងត្បូង ដែលប្រឹងប្រែងឥតឈប់ឈរដើម្បីកសាងប្រព័ន្ធអេកូឌីជីថលមួយដ៏រឹងមាំ និងសមត្ថភាពអនុវត្តសេដ្ឋកិច្ចឌីជីថលឲ្យដំណើរការបានយ៉ាងពេញលេញ។

២. បច្ចេកវិទ្យាឌីជីថល អាចជួយបង្កើនសមត្ថភាពវិស័យសាធារណៈ ពន្លឿនកំណែទម្រង់រដ្ឋបាលសាធារណៈ កែលំអគណនេយ្យភាព និងតម្លាភាពនៃអាជ្ញាធរថ្នាក់មូលដ្ឋាន និងសម្រួលឲ្យរដ្ឋាភិបាលអាចពាក់ព័ន្ធជាមួយសហគមន៍ និងប្រជាជនបានកាន់តែច្រើន និងមានប្រសិទ្ធភាពក្នុងចំណាយ។ បច្ចេកវិទ្យាឌីជីថលក៏អាចជួយពង្រឹងសហប្រតិបត្តិការ និងភាពជាដៃគូ រវាងក្រសួងមន្ទីរនិងស្ថាប័ននានាក្នុងទូទាំងប្រទេសដែរ។

៣. ដោយសារមានកំណើនក្រុមយុវជនប្រកបដោយការអប់រំល្អ និងជំនាញខ្ពស់ មានកំណើនយ៉ាងគំហុកនៃប្រើឧបករណ៍ឆ្លាតភ្ជាប់នឹងអ៊ិនធើណិត និងមានការជ្រាបសុសសាយយ៉ាងលឿននៃបច្ចេកវិទ្យាដែលទទួលបានតាមរយៈលំហូរចូលវិនិយោគផ្ទាល់ពីបរទេស កម្ពុជាក៏មានសមត្ថភាពអាចទាញយកចំណេញពីនិន្នាការនៃ ការប្រែក្លាយផ្នែកឌីជីថលដែលកំពុងជំរុញឧស្សាហកម្ម ៤.0។

៤. ការកសាងប្រព័ន្ធឌីជីថលទូទាំងប្រទេស នឹងជួយភ្ជិតគម្លាតឌីជីថលរវាងជនបទនឹងទីក្រុង និងនាំឲ្យមានកំណើននិងការអភិវឌ្ឍសេដ្ឋកិច្ចដែលអំណោយផលកាន់តែច្រើនដល់អាជីវកម្ម និងឧស្សាហកម្មក្នុងស្រុក និងក្រុមហ៊ុនចម្រុះទុនបែបថ្មី ហើយតាមនេះអាចជួយជំរុញសេដ្ឋកិច្ចនៅតំបន់ជនបទ។ លទ្ធភាពគ្រប់គ្នាក្នុងការប្រើប្រាស់ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងសារគមនាគមន៍ (ICT) គឺចាំបាច់បំផុតដើម្បីពង្រីកដែនគ្របដណ្តប់ គុណភាព និងជម្រើសនៃកម្មវិធីសិក្សាអប់រំ ព្រមទាំងបង្កើនកម្រិតជំនាញ ក្នុងនោះមានទាំងចំណេះដឹងផ្នែកឌីជីថលផង និងដើម្បីតភ្ជាប់សហគ្រាសខ្នាតតូចនិងមធ្យម (SMEs) ក្នុងមូលដ្ឋាន ជាមួយនឹងទីផ្សារក្នុងស្រុកនិងបរទេស និងជាមួយវិនិយោគផ្ទាល់ពីបរទេស។

### ស្ថានភាពនៃប្រព័ន្ធអេកូឌីជីថលនៅកម្ពុជា

ដើម្បីសម្រេចបានតាមយុទ្ធសាស្ត្រកំណើន ប្រកបដោយមហិច្ឆតារបស់ខ្លួន កម្ពុជាត្រូវត្រៀមខ្លួនឲ្យស្រេចបាច់ដើម្បីចាប់យកឱកាសល្អនៃសេដ្ឋកិច្ចឌីជីថល។ ការទទួលយកបច្ចេកវិទ្យាទើបផុសថ្មី អាចជួយជំរុញកំណើនពាណិជ្ជកម្មអេឡិចត្រូនិក ពង្រឹងការចូលរួមរបស់សហគ្រាសក្នុងស្រុកនៅក្នុងខ្សែសង្វាក់តម្លៃសកល និងសម្រួលឲ្យ SMEs និងសហគ្រាសទើបចាប់ដំណើរការ (startups) ងាយទទួលបានហិរញ្ញវត្ថុ។ ប៉ុន្តែប្រព័ន្ធអេកូឌីជីថលទើបកើតថ្មីនៅកម្ពុជានេះបាន

ឯកសារនេះសង្ខេបចំណុចសំខាន់ៗនៃការពិភាក្សាក្នុងសន្និសីទចក្ខុវិស័យប្រទេសកម្ពុជាឆ្នាំ២០១៩ដែលវិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (CDRI) និងក្រុមហ៊ុនGGearបានសហការគ្នារៀបចំឡើងនៅថ្ងៃទី២៦មីនា២០១៩។ ឯកសារនេះបានគូសរំលេចពីតម្រូវការធ្វើការប្រែក្លាយផ្នែកឌីជីថលបង្ហាញរូបភាពនៃការប្រែក្លាយផ្នែកឌីជីថលនៅកម្ពុជា និងជួយផ្តល់មតិផ្នែកគោលនយោបាយមួយចំនួន ដើម្បីអភិវឌ្ឍ និងជំរុញការប្រែក្លាយផ្នែកឌីជីថល។

**លទ្ធផលនៃ សន្និសីទចក្ខុវិស័យប្រទេសកម្ពុជា ឆ្នាំ២០១៩**
**ក្នុងកិច្ចសហការជាដៃគូរវាង វិទ្យាស្ថាន CDRI និងក្រុមហ៊ុន G Gear**

ប៉ះពាល់ដល់លទ្ធភាពរបស់អាជីវកម្ម និងអ្នកប្រើប្រាស់កម្ពុជា ដើម្បីទទួលយកបច្ចេកវិទ្យាថ្មីនិងនវានុវត្តន៍ ហើយតាមនេះបានប៉ះពាល់ដល់ល្បឿននិងវិសាលភាពនៃការជ្រាបសុសសាយបច្ចេកវិទ្យា។ កម្ពុជាសព្វថ្ងៃកំពុងនៅក្រោយគេបន្តិច ធៀបនឹងគូប្រកួតប្រជែងនៅក្នុងតំបន់។ ពិន្ទុភាពត្រៀមខ្លួនផ្នែកឌីជីថលសរុបរបស់កម្ពុជា ត្រឹម ៨,៦០ លើពិន្ទុពេញ ២៥ (ពិន្ទុទាបបំផុត ៥,៨៩ ពិន្ទុខ្ពស់បំផុត ២០,១០ ពិន្ទុមធ្យម ១១,៩៦ ក្នុងចំណោម ១១៨ប្រទេស) នៅក្នុងសន្ទស្សន៍ភាពត្រៀមខ្លួនផ្នែកឌីជីថលសកល (Cisco's Global Digital Readiness Index 2018) បានដាក់កម្ពុជានៅលំដាប់ទាបៗបំផុតនៃភាពត្រៀមខ្លួនផ្នែកឌីជីថល ពោលគឺ ខ្ពស់បន្តិចជាងមីយ៉ាន់ម៉ា ប៉ុន្តែទាបជាងឡាវ (៩,៤៨) ថៃ (១២,៥៣) វៀតណាម (១២,៥៦) ម៉ាឡេស៊ី (១៥,១៩) និង សិង្ហបុរី (១៨,៣០)[១]។

## *ហេដ្ឋារចនាសម្ព័ន្ធបច្ចេកវិទ្យា*

ហេដ្ឋារចនាសម្ព័ន្ធឌីជីថលស្នូលរបស់កម្ពុជា កំពុងល្អប្រសើរឡើង ប៉ុន្តែនៅផុយស្រួយនៅឡើយ។ ចំនួនប្រតិបត្តិករចល័តសកម្មទូទាំងប្រទេសបានកើនពី ៣ នៅឆ្នាំ២០០០ ដល់ ៦ នាបច្ចុប្បន្ន។ ប្រតិបត្តិករចម្បងៗ រួមមាន Smart Axiata, Vittel, CamGSM ។ ដោយសារហេដ្ឋារចនាសម្ព័ន្ធទូរស័ព្ទខ្សែនៅមានតិច ទូរស័ព្ទចល័តក៏រីកដុះដាលនៅកម្ពុជា ក្នុងនេះ បណ្តាញ 3G បានចាប់ដំណើរការនៅឆ្នាំ២០០៧ បណ្តាញល្បឿនលឿន 4G/LTE នៅឆ្នាំ២០១៤ ហើយបណ្តាញ 4.5G នៅឆ្នាំ២០១៧ ។ បណ្តាញប្រើខ្សែអចល័ត (fixed line broadband) មិនសូវពេញនិយមក៏ពិតមែន ប៉ុន្តែមានទីផ្សាររស់រវើកសម្រាប់សេវាទូរស័ព្ទអចល័តនេះ ហើយសព្វថ្ងៃមានប្រតិបត្តិករចំនួន ៨ កំពុងផ្គត់ផ្គង់វា។ នៅទូទាំងកម្ពុជា អ្នកផ្តល់សេវាអ៊ិនធើណិត មានសរុប ៣០ ក្រុមហ៊ុន និងមាន ៣ ក្រុមហ៊ុនទូរគមនាគមន៍ ដែលផ្តល់បណ្តាញខ្សែកាប្លអុបទិកមេ មានប្រវែងសរុប ២៧.១០០គ.ម នៅឆ្នាំ២០១៧។ ខ្សែកាប្លក្រោមសមុទ្រ ម៉ាឡេស៊ី-កម្ពុជា-ថៃ និង អាស៊ី-អាហ្វ្រិក-អឺរ៉ុប-១ បានតមកដល់ក្រុងព្រះសីហនុ នៅឆ្នាំ២០១៧។ ប្រព័ន្ធខ្សែកាប្លទាំងនេះបានបង្កើនភាពតភ្ជាប់ជាសកលរបស់ប្រទេសកម្ពុជា និងផ្តល់លទ្ធភាពមានសេវា ICT ប្រើប្រាស់ បានកាន់តែលឿន ថោក និងគួរឲ្យទុកចិត្ត។ សម្ព័ន្ធក្រុមហ៊ុនបច្ចេកវិទ្យាក្នុងស្រុក និងអន្តរជាតិមួយ កំពុងកសាងមជ្ឈមណ្ឌលផ្ទុកទិន្នន័យទំនើបបំផុតមួយកន្លែង ដែលរំពឹងថាអាចភ្ជាប់ប្រើការបាននៅដើមឆ្នាំ២០២០។ មជ្ឈមណ្ឌលបែបនេះ ជាទ្រព្យសកម្មសំខាន់បំផុតមួយសម្រាប់ប្រព័ន្ធអេកូឌីជីថលកម្ពុជា។ វានឹងជួយបង្កើនការផ្តល់សេវាឌីជីថល និងក្លោដ និងជួយទាក់ទាញមកពីបរទេសនូវវិនិយោគ បទពិសោធន៍ ចំណេះដឹងជំនាញការ និងប្រព័ន្ធសន្តិសុខអ៊ិនធើណិត។

## *ការទទួលយកបច្ចេកវិទ្យាឌីជីថល*

នៅឆ្នាំ២០១៧ ការចុះឈ្មោះជាវសេវាទូរស័ព្ទចល័តនៅកម្ពុជាមានកម្រិត ១១,៥% គឺខ្ពស់ជាងកម្រិតមធ្យមក្នុងតំបន់អាស៊ី-ប៉ាស៊ីហ្វិក។ ប៉ុន្តែកម្ពុជានៅចាញ់គេក្នុងរង្វាស់ជាច្រើន ដូចជា ការចុះឈ្មោះជាវសេវាអ៊ិនធើណិតតាមខ្សែអចល័ត (០,៨៣ ក្នុងមនុស្ស ១០០នាក់ ធៀបនឹងកម្រិតមធ្យម ១២,៥៦), អត្រាអ្នកប្រើអ៊ិនធើណិត[២] (៣៤,០% ធៀបនឹង ៤៤,៣%), គ្រួសារមានកុំព្យូទ័រ (១២,៥% ធៀបនឹង ៣៨,៨៤%), និងគ្រួសារមានអ៊ិនធើណិតប្រើ (២១,០% ធៀបនឹង ៤៩,០២%)[៣] ជាដើម។ សម្រាប់សហគ្រាស ប្រព័ន្ធអេកូឌីជីថលដែលកំពុងរីកចម្រើនស្របតាមកំណើននៃ ភាពល្បីឈ្មោះរបស់អ្នកមានឥទ្ធិពលក្នុងបណ្តាញសង្គម ប្រព័ន្ធពាណិជ្ជកម្មតាម អ៊ិនធើណិត (ឧទាហរណ៍ Alibaba) ប្រព័ន្ធទូទាត់តាមអ៊ិនធើណិត សេវាដឹកទំនិញដល់ផ្ទះ កម្មវិធីហៅយានដឹកភ្ញៀវ (ឧទាហរណ៍ PassApp) បានធ្វើឲ្យប្រែប្រួលជាខ្លាំងដល់គំរូអាជីវកម្មជាប្រពៃណី និងសេវាលក់រាយផ្សេងៗ។

កម្ពុជាត្រូវស្ទារយ៉ាងលឿននូវភាពនៅក្រោយគេកន្លងមកនេះ បើសិនចង់តាមឲ្យទាន់កម្រិតទទួលយកបច្ចេកវិទ្យាឌីជីថលរបស់ សហគ្រាស និងប្រជាជននៅក្នុងប្រទេសជាគូប្រកួតប្រជែងនានា។ ជាក់ស្តែង នៅឆ្នាំ២០១៧ អាជីវកម្មកម្ពុជាដែលមានវេបសាយ គឺមានមិនដល់ ២៥% ទេ ធៀបនឹង អត្រាមធ្យមសកលប្រមាណ ៤៦%។ ថ្វីបើនៅកម្ពុជាមានសហគ្រាសទើបចាប់ដំណើរការផ្នែកបច្ចេកវិទ្យាហិរញ្ញវត្ថុ (fintech startups) រហូតដល់ប្រមាណ ៥០ កំពុងធ្វើសកម្មភាពក្តី ប៉ុន្តែការទទួលយកសេវាហិរញ្ញវត្ថុឌីជីថល នៅមានល្បឿនយឺតក្នុងពេលកន្លងមក។ ជាក់ស្តែង នៅឆ្នាំ២០១៦ មានប្រជាជនកម្ពុជាតែ ១% ប៉ុណ្ណោះដែលប្រើទូរស័ព្ទចល័ត ឬអ៊ិនធើណិត ដើម្បីចូលប្រើគណនីនៅតាមស្ថាប័នហិរញ្ញវត្ថុ (ជាអត្រាទាបបំផុតនៅក្នុង Global Findex 2017)[៤] និងមានត្រឹម ១៦% ដែលធ្វើការទូទាត់ដោយប្រើប្រព័ន្ធឌីជីថល (ឧទាហរណ៍ PiPay) គឺនៅទាបជាខ្លាំងធៀបនឹង អត្រាមធ្យម ៥៨% សម្រាប់តំបន់អាស៊ី-ប៉ាស៊ីហ្វិកខាងកើត។

កង្វះខាតជំនាញបច្ចេកទេសនៅក្នុងកម្លាំងពលកម្ម ហើយនិងហេដ្ឋារចនាសម្ព័ន្ធផ្គត់ផ្គង់ឡូជីស្ទិកមិនទាន់គ្រប់គ្រាន់ គឺជាមូលហេតុចម្បងនៃការទទួលយកយឺតៗនូវបច្ចេកវិទ្យាឌីជីថលក្នុងទូទាំងប្រទេស។ រដ្ឋាភិបាលអេឡិចត្រូនិកនៅតែមានលក្ខណៈដាច់ដោយដុំ ពីព្រោះវេបសាយរបស់រដ្ឋាភិបាលនៅអន់ថយនិងរប៉ាត់រប៉ាយ សេវាសាធារណៈផ្តល់តាមអ៊ិនធើណិតនៅមានតិច ហើយ ប្រព័ន្ធទូទាត់ពហុភាគីមានលក្ខណៈប្រមូលផ្តុំ (centralised multilateral payment system) ក៏នៅខ្វះខាត។ អង្កេតលើរដ្ឋាភិបាលអេឡិចត្រូនិក របស់អង្គការសហប្រជាជាតិឆ្នាំ២០១៦ និង ២០១៨ បានដាក់ប្រទេសកម្ពុជាក្នុងក្រុម សន្ទស្សន៍អភិវឌ្ឍន៍រដ្ឋាភិបាលអេឡិចត្រូនិកថ្នាក់កណ្តាល (EDGI) ក្នុងនេះ ការកែលំអបានច្រើនជាងគេស្ថិតក្នុងសេវាអ៊ិនធើណិត ដោយកម្ពុជាមានពិន្ទុ EDGI កើនពី ០,០៥ ដល់ ០,២៥ (ពិន្ទុពេញ = ១)។

## *ក្របខ័ណ្ឌច្បាប់*

កម្ពុជាមិនទាន់មានក្របខ័ណ្ឌច្បាប់សព្វគ្រប់ល្អទេសម្រាប់ ប្រព័ន្ធអេកូឌីជីថលថ្មី។ សព្វថ្ងៃរដ្ឋាភិបាល កំពុងកសាងក្របខ័ណ្ឌច្បាប់និងគោលនយោបាយ ដើម្បីផ្តល់ការណែនាំឲ្យបានច្បាស់ដល់វិស័យ ICT ក្នុងនេះ ឯកសារព្រាងស្តីពី គោលនយោបាយជាតិលើវិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍ បានកំណត់យុទ្ធសាស្ត្រ ៤ គឺមាន ការធ្វើផែនការធនធានមនុស្ស, ការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធ និងស្ថាប័ន, ការលើកកម្ពស់ការស្រាវជ្រាវ, និង ការបង្កើតក្រសួងសម្រាប់វិទ្យាសាស្ត្របច្ចេកវិទ្យា និងនវានុវត្តន៍។ ផែនការមេថ្នាក់ជាតិផ្នែកវិទ្យាសាស្ត្រនិងបច្ចេកវិទ្យាឆ្នាំ២០១៤-២០ ដែលកម្ពុជាបានចាប់អនុវត្តនៅឆ្នាំ២០១៤ ផ្តោតជាសំខាន់លើ នវានុវត្តន៍ផ្នែកឧស្សាហកម្មក្នុងកសិកម្ម ឧស្សាហកម្មផលិតវត្ថុធាតុដើម និង ICT។ ផែនការមេផ្នែក ICT ឆ្នាំ២០២០ ដែលកម្ពុជាបានអនុម័តចេញក្នុងឆ្នាំ២០១៤ ផ្តោតជាសំខាន់លើ ការផ្តល់

១ Tae Yoo, Mary de Wysocki and Amanda Cumberland. 2018. *Country Digital Readiness: Research to Determine a Country's Digital Readiness and Key Interventions*. www.cisco.com/c/dam/assets/csr/pdf/Country-Digital-Readiness-White-Paper-US.pdf.

២ មាននិយមន័យថាជា បុគ្គលប្រើប្រាស់អ៊ិនធើណិត (តាមរយៈ កុំព្យូទ័រ ទូរស័ព្ទចល័ត កូនកុំព្យូទ័រ (personal digital assistant) ម៉ាស៊ីនលេងហ្គេម ទូរទស្សន៍ឌីជីថល ...) នៅក្នុងទីតាំងណាមួយ

៣ ITU. 2018. *World Telecommunication / ICT Indicators Database 2017* (version 1.0.1).

៤ Natasha Beschorner, James Neumann, Miguel Eduardo Sanchez Martin. 2018. *Benefiting from the Digital Economy: Cambodia Policy Notes*. Washington, DC: World Bank.

សិទ្ធិអំណាចឲ្យប្រជាជន ការជានាំឲ្យមានភាពតភ្ជាប់ ការលើកកម្ពស់សមត្ថភាព និង ការពង្រឹងសេវាអេឡិចត្រូនិក។ ឯកសារនេះក៏ផ្តល់ការណែនាំសម្រាប់យុទ្ធសាស្ត្រ និងគោលនយោបាយផ្នែក ICT ដែរ។ គោលនយោបាយអភិវឌ្ឍន៍ទូរគមនាគមន៍ និង ICT (T-ICT) ឆ្នាំ២០២០ ដែលប្រកាសចេញក្នុងឆ្នាំ២០១៦ មានគោលដៅលើកកម្ពស់ភាពតភ្ជាប់ និងភាពត្រៀមខ្លួនស្រេចផ្នែក ICT របស់កម្ពុជា តាមការកែលំអប្រព័ន្ធសន្តិសុខអ៊ីនធើណិត និងការដាក់បញ្ចូល ICT ទៅក្នុងឧស្សាហកម្ម ការជំរុញការប្រើប្រាស់ ICT និងការកសាងគ្រឹះរឹងមាំសម្រាប់ការអភិវឌ្ឍ ICT។ អនុក្រឹត្យលេខ ២៤៦ ស្តីពី ហត្ថលេខាអេឡិចត្រូនិក ត្រូវបានអនុម័តចេញនៅខែធ្នូ ២០១៧។ ប៉ុន្តែក្របខ័ណ្ឌច្បាប់ភាគច្រើនសម្រាប់ប្រព័ន្ធអេកូឌីជីថល ដូចជាស្តីពី កិច្ចការជំនួញអេឡិចត្រូនិក កិច្ចការពារអ្នកប្រើប្រាស់សម្រាប់ការទិញតាមអ៊ីនធើណិត និង ការទប់ស្កាត់បទល្មើសតាមអ៊ីនធើណិត ជាដើម កំពុងស្ថិតក្នុងដំណាក់កាលតាក់តែងនៅឡើយ។

## កម្លាំងពលកម្មផ្នែកឌីជីថល

ចំណេះដឹងផ្នែកឌីជីថលដែលនៅមានកម្រិតទាប កង្វះសមត្ថភាពបច្ចេកទេស និងកង្វះជំនាញទន់ដ៏ចាំបាច់ៗ ដូចជា ភាពច្នៃប្រឌិត កិច្ចសហការ ការប្រស្រ័យទាក់ទង ការគិតគូរវិភាគ និងការដោះស្រាយបញ្ហា នៅតែជាបញ្ហាប្រឈមមួយយ៉ាងធំ នៅគ្រប់កម្រិតនៃកម្លាំងពលកម្ម។ ជាក់ស្តែង មូលហេតុចម្បងនៃចំណាត់ថ្នាក់ទាបរបស់កម្ពុជា (ទី១១០ ក្នុងចំណោម ១៤០ប្រទេស) នៅក្នុង សន្ទស្សន៍ភាពប្រកួតប្រជែងសកល ៤.0 (GCI 4.0) ថ្មី ដែលទើបមានចុះក្នុង របាយការណ៍ភាពប្រកួតប្រជែងសកលឆ្នាំ២០១៨ គឺ កង្វះជំនាញគិតគូរវិភាគក្នុងចំណោមប្រជាជន។ សម្រាប់ជំនាញទូទៅ កម្ពុជាស្ថិតនៅចំណាត់ថ្នាក់ទី១២១ ដោយមានពិន្ទុ ៤១ (ពិន្ទុពេញ = ១០០)។ សម្រាប់ជំនាញផ្នែកឌីជីថល កម្ពុជាស្ថិតនៅចំណាត់ថ្នាក់ទី ១០៧ ដោយបានពិន្ទុ ៤៣,៥ គឺនៅក្រោយ វៀតណាម (បានពិន្ទុ ៤៤,៦) ឡាវ (៤៨,៥) ថៃ (៥៦,២) ម៉ាឡេស៊ី (៧៣,១) សិង្ហបុរី (៧៧,៧)។[៥] ទោះបីជាមានការពង្រីកដែនគ្របដណ្តប់នៃអ៊ីនធើណិតល្បឿនលឿនក្តី (ពី ២២,៣៣% ក្នុងឆ្នាំ២០១៥ ដល់ ៣៤% ក្នុងឆ្នាំ២០១៧) ប៉ុន្តែចំណាប់អារម្មណ៍ និងចំណេះដឹងផ្នែកឌីជីថលរបស់ប្រជាជននៅទាបជាខ្លាំង។ អ្នកប្រើប្រាស់ជាច្រើននាក់ពឹងផ្អែកលើអ៊ីនធើណិតសម្រាប់ការកំសាន្ត និងការចូលក្នុងបណ្តាញសង្គមជាសំខាន់ គឺមិនមែនដើម្បីបង្កើនផលិតភាព ដូចជារៀនយកជំនាញថ្មីៗទៀត នោះទេ។

## ករណីជាក់ស្តែងពីរនៃជោគជ័យក្នុងការប្រែក្លាយផ្នែកឌីជីថល

គេតែងចាត់ទុកសិង្ហបុរីជា ប្រទេសមានសេដ្ឋកិច្ចឌីជីថលឈានមុខគេមួយលើពិភពលោក។ រដ្ឋាភិបាលសិង្ហបុរីដើរតួនាទីសំខាន់ណាស់ក្នុងការជំរុញ និងទាញយកចំណេញពីការប្រើប្រាស់ប្រព័ន្ធឌីជីថលដោយផ្តោតលើអាទិភាពជាយុទ្ធសាស្ត្រ ចំនួន ៣ គឺ ការប្រើប្រាស់ប្រព័ន្ធឌីជីថលក្នុងឧស្សាហកម្មនានា ការបន្សុីចូលគ្នានូវប្រព័ន្ធអេកូផ្សេងៗ និងការធ្វើឲ្យ ប្រព័ន្ធឌីជីផលមានលក្ខណៈដូចឧស្សាហកម្ម។ រដ្ឋាភិបាលបានផ្តល់ជំនួយគាំទ្រជាប់រហូតដល់អាជីវកម្មនានា ជាពិសេស សហគ្រាសខ្នាតតូចនិងមធ្យម (SMEs) ដើម្បីកសាង និងកែសម្រួលជាបន្តបន្ទាប់នូវហេដ្ឋារចនាសម្ព័ន្ធឌីជីថលរបស់ខ្លួន និងពង្រីកព្រំដែននៃនវានុវត្តន៍។ រដ្ឋាភិបាលជួយឲ្យអាជីវកម្មនានាអាចរីកចម្រើន ពង្រីកទំហំ និងដែនសកម្មភាព និងជួយដោះស្រាយបញ្ហាបន្ទាន់ផ្សេងៗ ព្រមទាំងជួយលើកទឹកចិត្តដល់ អ្នកមានជំនាញខ្ពស់ៗដែលទើបផុសថ្មី និងនវានុវត្តន៍។ ឧស្សាហកម្មឌីជីថលទើបផុសថ្មីដែលបង្កការអាក់អួលទាំងនេះ គេបានថែបំប៉ន និងយកមកធ្វើជាកម្លាំងថ្មីដើម្បីជំរុញកំណើនសេដ្ឋកិច្ច។ ដើម្បីទទួលបានជោគជ័យក្នុងកិច្ចប្រឹងប្រែងនេះ សិង្ហបុរីដោយឥតឈប់ឈរ បានលើកកម្ពស់ជំនាញផ្សេងៗផ្នែកឌីជីថលរបស់កម្លាំងពលកម្ម និងធ្វើវិនិយោគក្នុងការស្រាវជ្រាវ និងនវានុវត្តន៍។ ហេដ្ឋារចនាសម្ព័ន្ធ អភិបាលកិច្ច គោលនយោបាយ និងស្តង់ដានានា ត្រូវបានកែលំអជាបន្តបន្ទាប់ ដើម្បីសម្រួលដល់ការជឿនលឿនផ្នែកឌីជីថល។

បទពិសោធន៍ក្នុងការប្រែក្លាយផ្នែកឌីជីថលរបស់ថៃ គួរឲ្យចាប់អារម្មណ៍ណាស់។ សម្រាប់សមត្ថភាពប្រកួតប្រជែងផ្នែកឌីជីថល ថៃជាប់ចំណាត់ថ្នាក់ក្នុងចំណោមបីប្រទេសលើគេនៅក្នុងតំបន់ និងជាប់ចំណាត់ថ្នាក់ទី៣៩ ក្នុងពិភពលោក។ លទ្ធផលដ៏ល្អនេះផុសចេញពីការប្រឹងប្រែងឥតឈប់ឈររបស់ថៃ ក្នុងការអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធទន់ ហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងមូលធនមនុស្ស។ ចាប់ពីឆ្នាំ២០០៥ មក រដ្ឋាភិបាលថៃបានដាក់អនុវត្តក្របខ័ណ្ឌឌីជីថលផ្សេងៗ មានជាអាទិ៍ ប្រទេសថៃ ៤.0, ផែនការមេសេដ្ឋកិច្ចឌីជីថលជាតិ និងច្បាប់ជាច្រើនទៀតខាងផ្នែកឌីជីថល ហើយតាមនេះបានកសាងឡើងនូវ ហេដ្ឋារចនាសម្ព័ន្ធឌីជីថលថ្មីមួយ។ ក្នុងឆ្នាំ២០១៧ រដ្ឋាភិបាលបានបើកដំណើរការឧទ្យានឌីជីថលថៃ ដើម្បីបម្រើការជាមជ្ឈមណ្ឌលសេវាឌីជីថល បានពង្រីកលទ្ធភាពប្រើប្រាស់ប្រព័ន្ធខ្សែកាបក្រោមសមុទ្រ បានថែបំប៉នអ្នកមានជំនាញខ្ពស់ៗ និងបានលើកកម្ពស់នវានុវត្តន៍។ គម្រោងអ៊ីនធើណិតតាមភូមិ (Net Pracharat) បានចាប់អនុវត្តក្នុងឆ្នាំជាមួយគ្នា ដើម្បីឲ្យគ្រួសារក្រីក្រក្នុងជាង ២៤.000ភូមិ មានលទ្ធភាពបានប្រើប្រាស់អ៊ីនធើណិតល្បឿនលឿនក្នុងតម្លៃសមរម្យ។ ដើម្បីកសាងកម្លាំងពលកម្មមានជំនាញឌីជីថល ថៃបានចាប់អនុវត្តនាពេលថ្មីៗនូវ ទិដ្ឋាការឆ្លាត (SMART Visa) ដើម្បីទាក់ទាញពលករមានជំនាញខ្ពស់ពីក្រៅប្រទេសមកបំពេញបន្ថែមលើ ពលករមានជំនាញខ្ពស់ដែលបណ្តុះបណ្តាលបាននៅក្នុងស្រុក។

## គោលនយោបាយលើការប្រែក្លាយផ្នែកឌីជីថលនៅកម្ពុជា

កម្ពុជាបានអនុវត្តគំនិតផ្តួចផ្តើមជាច្រើន ដើម្បីជំរុញទៅមុខនូវការប្រែក្លាយផ្នែកឌីជីថល។ គោលនយោបាយលើហេដ្ឋារចនាសម្ព័ន្ធ ICT និងច្បាប់នានា បង្ហាញពីកិច្ចប្រឹងប្រែងរបស់កម្ពុជាដើម្បីកសាងបរិស្ថានឌីជីថលមួយមានសុវត្ថិភាពល្អ រឹងមាំ និងសម្រាប់គ្រប់គ្នា ដែលក្នុងនោះគំនិតច្នៃប្រឌិត និងនវានុវត្តន៍ផ្នែកឌីជីថល អាចរីកចម្រើនបាន។ រដ្ឋាភិបាលក៏កំពុងជំរុញការប្រើប្រាស់របស់ខ្លួននូវប្រព័ន្ធឌីជីថល តាមរយៈ ការប្រើប្រព័ន្ធឌីជីថលក្នុងការផ្តល់សេវាសាធារណៈមួយចំនួន ដូចជាក្នុង នីតិវិធីចុះបញ្ជីពាណិជ្ជកម្មកំណត់ឡើងដោយ ក្រសួងពាណិជ្ជកម្ម និងក្នុង នីតិវិធីចេញទិដ្ឋាការទេសចរណ៍សម្រាប់ការចេញចូលមួយដងកំណត់ឡើងដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ។

រដ្ឋាភិបាលកំពុងបង្កើត ធនាគារជាតិសម្រាប់សហគ្រាសខ្នាតតូច និងមធ្យម និង មជ្ឈមណ្ឌលគេដោសម្រាប់សហគ្រាសទើបបើកថ្មី ក្នុងចំណោមវិធានការឧបត្ថម្ភគាំទ្រជាច្រើនទៀត ដើម្បីជួយឲ្យអាជីវកម្មនានាអាចអនុវត្តគំនិតបែបថ្មី និងរីកចម្រើនឡើង។ សកម្មភាពផ្នែកគោលនយោបាយជាច្រើនរបស់រដ្ឋាភិបាល បានផ្តោតលើ ការកសាងមូលធនមនុស្សសម្រាប់សេដ្ឋកិច្ចឌីជីថល។ នៅឆ្នាំ២០១៤ ក្រុមប្រឹក្សាជាតិវិទ្យាសាស្ត្រ និងបច្ចេកវិទ្យា ត្រូវបានបង្កើតឡើង ដើម្បីធ្វើការគ្រិតគម្លាតសមត្ថភាពផ្នែកបច្ចេកវិទ្យារវាងប្រទេសកម្ពុជា នឹងប្រទេសដទៃទៀត។ ស្របតាម គោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មឆ្នាំ២០១៥-២៥ ដែលបានសង្កត់ធ្ងន់លើសារៈសំខាន់នៃវិទ្យាសាស្ត្រ និងបច្ចេកវិទ្យាសម្រាប់ការ

៥ World Economic Forum. 2018. *Cambodia: Global Competitiveness Index 4.0 2018 Edition.*

អភិវឌ្ឍប្រទេស ក្រសួងអប់រំយុវជននិងកីឡា កំពុងផ្សព្វផ្សាយពីការអប់រំផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និង គណិតវិទ្យា (STEM) នៅតាមសាលារៀននៅគ្រប់កម្រិត។ ដោយសារការផ្លាស់ប្តូរផ្នែកបច្ចេកវិទ្យា និងការប្រកួតប្រជែងកាន់តែមានសន្ទុះខ្លាំង ដូច្នេះគោលនយោបាយលើការអប់រំបណ្តុះបណ្តាលបច្ចេកទេសនិងវិជ្ជាជីវៈ (TVET) ឆ្នាំ២០១៧-២៥ របស់កម្ពុជា បានកំណត់ឲ្យផលិតបានកាន់ច្រើននូវពលករមានជំនាញ និងអ្នកបច្ចេកទេស។ ការបង្កើតមូលនិធិជាតិសម្រាប់អភិវឌ្ឍន៍ជំនាញ គឺជា ជំហានមួយនាពេលថ្មីៗ ដើម្បីជួយឲ្យកម្លាំងពលកម្មសព្វថ្ងៃអាចបង្កើនជំនាញរបស់ខ្លួនបាន។

សេដ្ឋកិច្ចឌីជីថលរបស់កម្ពុជា កំពុងស្ថិតក្នុងដំណាក់កាលទើបចាប់ផ្តើម ហើយកម្ពុជាមិនទាន់មានគោលនយោបាយសេដ្ឋកិច្ចឌីជីថលពេញលេញជាក់លាក់នៅឡើយទេ។ ទោះយ៉ាងនេះក្តី ក្នុងខែមករា ២០១៩ រដ្ឋាភិបាលបានបង្កើតក្រុមការងារបច្ចេកទេស ដើម្បីកសាងក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ចឌីជីថល សម្រាប់ធ្វើជា ផែនទីបង្ហាញផ្លូវជាផ្លូវការ ដើម្បីចាប់យកឱកាសល្អផុសចេញពីបដិវត្តន៍ឌីជីថលសម្រាប់ការអភិវឌ្ឍសេដ្ឋកិច្ចសង្គមកិច្ចបន្ថែមទៀតដោយផ្តោតលើ ១) ការកសាងហេដ្ឋារចនាសម្ព័ន្ធឌីជីថល និងការអភិវឌ្ឍប្រព័ន្ធទូទាត់អេឡិចត្រូនិក និងបណ្តាញឡូជីស្ទិក ២) ការបង្កើតវេទិកាឌីជីថល និងការអភិវឌ្ឍប្រព័ន្ធអេកូឌីជីថល និង ៣) ការលើកកម្ពស់រដ្ឋាភិបាលអេឡិចត្រូនិក សហគ្រិនភាព ចំណេះដឹងផ្នែកឌីជីថល និងទិន្នន័យបើកចំហ (open data)។

## និសដៅជាយុទ្ធសាស្ត្រ និងការផ្តល់មតិផ្នែកគោលនយោបាយ

ប្រទេសកម្ពុជាមានសក្តានុពលច្រើន ដើម្បីលោតផ្លោះចូលទៅដល់សេដ្ឋកិច្ចនិងសង្គមឌីជីថល ដែលក្នុងនោះ មនុស្សមានសមត្ថភាពផ្នែកឌីជីថល និងគ្រប់វិស័យសុទ្ធតែប្រើប្រព័ន្ធឌីជីថល ហើយក្របខ័ណ្ឌច្បាប់ក៏អំណោយផលដល់នវានុវត្តន៍ដែរ។ ការពិពណ៌នាសង្ខេបនៅខាងលើពីការជឿនលឿនរបស់កម្ពុជា ក្នុងការប្រើប្រព័ន្ធឌីជីថលក្នុងសេដ្ឋកិច្ចបង្ហាញច្បាស់ថា កម្ពុជាកំពុងស្ថិតលើផ្លូវត្រូវ។ តទៅមុខទៀត នៅមានបញ្ហាជាច្រើនដែលត្រូវដោះស្រាយ និងមានវិស័យជាច្រើនដែលត្រូវបន្តការអភិវឌ្ឍ ប៉ុន្តែគេអាចប្រមើលឃើញជាស្រេចនូវ អនាគតដ៏ភ្លឺថ្លា។

ដោយបានយល់ច្បាស់ពីកន្លែងឈរជើងរបស់កម្ពុជា និងបានរៀនសូត្រពីករណីមានជោគជ័យទាំងពីរ ការសិក្សានេះមានផ្តល់មតិបីយ៉ាងលើការប្រែក្លាយផ្នែកឌីជីថលរបស់កម្ពុជាដើម្បីចូលទៅដល់ដំណាក់កាលបន្ទាប់នៃ សេដ្ឋកិច្ចឌីជីថលដូចបានប្រមើលឃើញ៖

១. *អភិវឌ្ឍប្រព័ន្ធអេកូមួយដ៏រឹងមាំ មានប្រសិទ្ធភាព និងប្រកបដោយនវានុវត្តន៍៖* ប្រព័ន្ធអេកូបែបនេះ អាចជួយបណ្តុះអ្នកប្រើប្រព័ន្ធឌីជីថលថ្មីៗ ផ្តល់ដំណោះស្រាយផ្នែកបច្ចេកវិទ្យា និងឱកាសមានកំណើន សម្រាប់ការប្រែក្លាយប្រទេសកម្ពុជាទៅជាសេដ្ឋកិច្ចឌីជីថលមួយដ៏រឹងមាំ។ ទាំងអស់នេះទាមទារឲ្យមានលក្ខខណ្ឌអំណោយផល និងការគាំទ្រ ដូច្នេះត្រូវមានកិច្ចសហការរវាងវិស័យឯកជននឹងវិស័យសាធារណៈ និងត្រូវដាក់អនុវត្តវិធានការមួយចំនួនដើម្បី៖

- ជំរុញការប្រកួតប្រជែង ក្នុងការផ្តល់បណ្តាញមានល្បឿនលឿន និងការធ្វើវិនិយោគលើហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដើម្បីឲ្យមានសេវាឌីជីថលកាន់តែលឿន មានតម្លៃទាប និងអាចដំណើរការបាននៅតាមជនបទ និងតំបន់ដាច់ស្រយាល។
- កសាងតំបន់ឌីជីថលផ្សេងៗ ដោយមានភ្ជាប់ជាមួយផងនូវគ្រឿងលើកទឹកចិត្តផ្នែកពាណិជ្ជកម្ម ពន្ធដារ និងហិរញ្ញវត្ថុ ដើម្បីទាក់ទាញទាំងអ្នកនៅក្នុងប្រទេស និងនៅក្រៅប្រទេស ដែលមានគំនិតបែបថ្មីក្នុងការធ្វើអាជីវកម្ម។
- លើកទឹកចិត្តឲ្យមានការចំណាយកាន់តែច្រើន លើការស្រាវជ្រាវ និងអភិវឌ្ឍន៍ នៅតាមអង្គភាពឯកជននិងសាធារណៈ ដើម្បីអាចកំណត់ឃើញនូវឱកាសល្អផ្នែកឌីជីថលសំខាន់ៗ និងថ្មីៗទៀត។
- បង្កើតកម្មវិធីភាពជាដៃគូ ប្រកបដោយនវានុវត្តន៍ជាច្រើនទៀតជាមួយនឹងរដ្ឋាភិបាលនៃ បណ្តាប្រទេសមានប្រព័ន្ធឌីជីថលឈានមុខគេនៅលើសកលលោក ដើម្បីអាចទទួលបានជំនួយអភិវឌ្ឍន៍សម្រាប់ការកែលំអកម្រិតនវានុវត្តន៍នៅកម្ពុជា។

២. *លើកកម្ពស់ចំណេះដឹង និងជំនាញជាមូលដ្ឋាន*។ ក្នុងសម័យឌីជីថលនេះ កម្លាំងពលកម្មទាំងមូលត្រូវតែមាន សមត្ថភាពផ្នែកឌីជីថល ដើម្បីអាចដើរទាន់ល្បឿនយ៉ាងលឿននៃការរីកលូតលាស់ផ្នែកបច្ចេកវិទ្យា និងទាញយកអត្ថប្រយោជន៍បានយ៉ាងពេញលេញ។ ក្នុងនេះរដ្ឋាភិបាលគួរតែ៖

- ពង្រីកពង្រឹងការផ្សព្វផ្សាយពី ការអប់រំនិងអាជីពផ្នែកវិទ្យាសាស្ត្រ បច្ចេកវិទ្យា វិស្វកម្ម និងគណិតវិទ្យា (STEM) សីលធម៌ផ្នែកឌីជីថល និងការរៀនសូត្រពេញមួយជីវិត ដើម្បីពង្រីកក្រុមអ្នកមានជំនាញខ្ពស់។
- ជួយគាំទ្រដល់ពលករនៅគ្រប់វិស័យនិងគ្រប់កម្រិត ទាំងក្នុងការបង្កើនជំនាញ និងការបង្រៀនជំនាញជាថ្មី ដើម្បីឲ្យពលករអាចសម្របខ្លួនទៅតាម តម្រូវការទីផ្សារការងារ ដែលកំពុងមានសន្ទុះខ្លាំង។
- បង្កើតមន្ទីរពិសោធន៍ សម្រាប់ការបណ្តុះបណ្តាលផ្នែកឌីជីថលដែលមានតម្លៃសមរម្យអាចប្រើប្រាស់បាន និងកម្មវិធីផ្តល់វិញ្ញាបនបត្រតាមអ៊ិនធើណិត សម្រាប់ជំនាញផ្សេងៗផ្នែកឌីជីថល ដើម្បីជួយសម្រួលដល់ការរៀនសូត្រ។
- បង្កើតគោលនយោបាយលើកទឹកចិត្ត ដើម្បីអាចថែរក្សានូវពលករមានសមត្ថភាពផ្នែកឌីជីថល ដែលបណ្តុះបណ្តាលបាននៅក្នុងស្រុក និងដើម្បីអាចទាក់ទាញពលករមានជំនាញខ្ពស់ពីក្រៅស្រុក។

៣. *គោរពតាមបទប្បញ្ញត្តិ និងស្តង់ដានានា*។ បច្ចេកវិទ្យា គឺជាអាវុធមានមុខពីរ។ ជាមួយគ្នានឹងអត្ថប្រយោជន៍វិជ្ជមានជាច្រើន វាក៏អាចបង្កនូវការគំរាមកំហែងផ្នែកសង្គម សេដ្ឋកិច្ច និងនយោបាយផងដែរ។ សកម្មភាពដើម្បីញាំងឲ្យប្រទេសជាតិ អាចទប់ទល់នឹងឥទ្ធិពលអវិជ្ជមានទាំងនេះ មិនត្រឹមជួយពង្រឹងទំនុកចិត្តប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយឲ្យប្រទេសជាតិ ស្ថិតលើផ្លូវត្រូវតទៅមុខទៀត។ កិច្ចការនេះចាំបាច់ណាស់ ដើម្បីឲ្យរដ្ឋាភិបាលអាច៖

- ពន្លឿនការតាក់តែងច្បាប់ បទប្បញ្ញត្តិ និងគោលនយោបាយជាពិសេសជាប់ទាក់ទងនឹង ប្រតិបត្តិការជំនួញតាមប្រព័ន្ធអេឡិចត្រូនិក កិច្ចការពារអ្នកប្រើប្រាស់សម្រាប់ការទិញតាមអ៊ិនធើណិត និងការទប់ស្កាត់បទល្មើសតាមអ៊ិនធើណិត។
- ដាក់អនុវត្តច្បាប់ស្តីពី ការការពារទិន្នន័យ ឬព័ត៌មានឯកជនក្នុងអ៊ិនធើណិត និងបញ្ហាជាប់ទាក់ទិនផ្សេងៗទៀត។

**វិទ្យាស្ថានបណ្តុះបណ្តាល និង ស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា (វបសអ/CDRI)**
អគារលេខ ៥៦ ផ្លូវ ៣១៥ ទួលគោក ប្រអប់សំបុត្រលេខ ៦២២ ភ្នំពេញ កម្ពុជា
+៨៥៥២៣ ៨៨១ ៣៨៤, ៨៨១ ៧០១, ៨៨១ ៩១៦, ៨៨៣ ៦០៣
email: cdri@cdri.org.kh, website: www.cdri.org.kh
បោះពុម្ពដោយ រោងពុម្ព Go Invent Media (GIM), ភ្នំពេញ